REPORTERS
WITHOUT BORDERS
FOR PRESS FREEDOM




# លោកនាយករដ្ឋមន្ត្រី លោកធ្លាប់បានសន្យាថា អ្នកកាសែតនឹងមិនត្រូវគេចាប់ដាក់គុកទៀតទេ។

ខែកុម្ភៈ ២០១០

អត្ថបទស៊ើបអង្កេត: Vincent Brossel
ការិយាល័យអាស៊ី អ្នកយកព័ត៌មានគ្មានព្រំដែន
៤៧ ផ្លូវ វីវៀន ៧៥០០២ ប៉ារីស
ទូរស័ព្ទ (៣៣) ១៤៤៨៣៨៤៨៤
ហ្វាក់៖ (៣៣) ១៤៥២៣១១៥១
អ៊ីម៉ែល៖ asie@rsf.org
Web : www.rsf.org

កម្ពុជា
របាយការណ៍បេសកកម្ម

# លោកនាយករដ្ឋមន្ត្រី លោកធ្លាប់បានសន្យាថា អ្នកកាសែតនឹងមិនត្រូវគេចាប់ដាក់គុកទៀតទេ

លោក នាយករដ្ឋមន្ត្រីហ៊ុន សែនបានបញ្ជាក់កាលពី ដើមឆ្នាំ២០០៦ថា ៖ អ្នកកាសែតកម្ពុជានឹងមិនត្រូវជាប់គុកដោយសារការសរសេរអត្ថបទរបស់ខ្លួនទៀតទេ។ ប៉ុន្តែ ៤ ឆ្នាំក្រោយពីការប្រកាសនេះ និងការធ្វើការកែទម្រង់ច្បាប់ ចាងហ្វាងកាសែតម្នាក់ត្រូវគេចាប់ដាក់គុកក្នុងលក្ខខ័ណ្ឌដ៏លំបាក។

ការផ្តន្ទាទោសឲ្យជាប់គុករយៈពេលមួយឆ្នាំ ដល់លោក ហង្ស ចក្រា ចាងហ្វាងកាសែតប្រឆាំង ខ្មែរម្ចាស់ស្រុកហាក់ដូចជាសំលេងព្រមានមួយដល់អ្នកកាសែតខ្មែរគ្រប់រូប។

ការសែតប្រចាំថ្ងៃនេះ ដែលមានចំនួនចេញ ផ្សាយតិចតួច និងមាននិន្នាការស្និទនឹងគណបក្សប្រឆាំង សម រង្ស៊ី គឺជាកាសែតមួយក្នុងចំណោមកាសែតតិចតួចដែលរិះគន់យ៉ាងសម្បើមដល់អាជ្ញាធរ។

ជាការពិត ក្នុងរយៈពេលតិចជាង ២ឆ្នាំនេះ កាសែតប្រឆាំងបានថយចុះចំនួនរបស់ខ្លួនជាបន្តបន្ទាប់។ ឧទាហរណ៍ កាសែតខ្មែរម្ចាស់ស្រុក និងកាសែតសេរីភាពថ្មីដែលបានបិទទ្វាររបស់ខ្លួនដោយហេតុផលគំរាមកំហែង ការខ្វះហិរញ្ញវត្ថុ ឬដោយមានសំណើឲ្យចុះចូលទៅខាងអាជ្ញាធរ។

ហេតុអ្វីបានជាលោកហ៊ុន សែនរំលឹកជាថ្មីនូវការសន្យារបស់ខ្លួន? ជាមួយនឹងការដាក់ឲ្យប្រើប្រាស់នូវច្បាប់ក្រមព្រហ្មទណ្ឌថ្មី តើគេកំពុងរង់ចាំអ្វីពីអង្គច្បាប់មួយនេះសម្រាប់សារព័ត៌មាន?

អ្នកតំណាងរបស់អង្គការអ្នកយកពត៌មានគ្មានព្រំដែនបានទៅប្រទេសកម្ពុជា នៅខែ ធ្នូ ឆ្នាំ ២០០៩ ដើម្បីវាយតម្លៃពីស្ថានភាពសេរីភាពសារព័ត៌មាន និងការពារ បុព្វហេតុនៃការលើកលែងការដាក់ទោសទណ្ឌបានទៅលើសារព័ត៌មាន នៅចំពោះមុខអាជ្ញាធរនៃព្រះរាជាណាចក្រ។ តំណាងរបស់អង្គការបានចូលជួបរដ្ឋមន្ត្រីក្រសួងព័ត៌មាន មន្ត្រីការទូត ចាងហ្វាងកាសែត អ្នកកាសែត អ្នកតំណាងគណបក្សប្រឆាំង និងអ្នកទទួលខុសត្រូវរបស់អង្គការការពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។

លោកខៀវ កញ្ញារិទ្ធ រដ្ឋមន្ត្រី ក្រសួងព័ត៌មានបានប្រកាសថា រូបលោកផ្ទាល់ចង់មានការដោះលែងលោក ហង្ស ចក្រា។ លោកបានបញ្ជាក់ថា ៖ ខ្ញុំខិតស៊ូយ៉ាងលំបាកដើម្បីមិនចង់ឃើញអ្នកកាសែតជាប់គុក ប៉ុន្តែ សារព័ត៌មានមួយចំនួនមិនបានគោរពច្បាប់ និងក្រមសីលធម៌សារព័ត៌មានទេ។

វត្តមាននៃប្រព័ន្ធផ្សព្វផ្សាយដែលមានលក្ខណៈឯករាជ្យ និងរិះគន់ ជាពិសេសនៅ តាមរលកធាតុអាកាស គឺ ជាការធានាថា របបមួយមិនមែនជារបបផ្តាច់ការ។ លោកប៉ែន សមិទ្ធី ប្រធានក្លឹបអ្នកកាសែតកម្ពុជាដែលប្រមូលផ្តុំនូវសមាជិកជាច្រើនរយនាក់ បានពន្យល់ថា ៖ អ្នកកាសែតមិនបានឈរឱបដៃដោយមិនធ្វើអ្វីនោះទេ។ ទន្ទឹមនឹងនោះ ភាពរីកចំរើនក្នុងប្រព័ន្ធផ្សព្វផ្សាយបានធ្វើឲ្យគុណភាពនៃការផ្តល់ដំណឹងបោះជំហានទៅមុខ។ ប៉ុន្តែ ប្រាកដណាស់ អ្នកកាសែតមួយចំនួនក្នុងចំណោមពួកយើងកំពុងប្រឈមមុខទៅនឹងការដាក់គំនាប និងការគំរាមកំហែងទៅលើរូបរាងកាយ។

នៅក្នុងរបាយការណ៍មួយដែលចេញផ្សាយ នៅឆ្នាំ ២០០៩ អង្គការសម្ព័ន្ធកម្ពុជាដើម្បីជួយ និងការពារសិទ្ធិមនុស្ស ដែលហៅកាត់ថា លីកាដូ បានអះអាងថា ទូរទស្សន៍ទាំង ៨ដែលកំពុងមានសកម្មភាពបច្ចុប្បន្នមានទំនាក់ទំនងទៅនឹងគណបក្សកាន់អំណាច ហើយមានតែវិទ្យុ ៤ប៉ុណ្ណោះក្នុងចំណោមវិទ្យុទាំងអស់ជាងដប់ ដែលឯករាជ្យ ឬមាននិន្នាការទៅរកគណបក្សប្រឆាំង។ សូមអានរបាយការណ៍លើគេហទំព័រ http://www.licadho-cambodia.org/reports.php?perm=130&pagenb=0&filter=-1&topic=1

ចាប់តាំងពី ដើមខែមករា ឆ្នាំ ២០០៩មក បណ្ដឹងជាង ១០ត្រូវបានធ្វើឡើងប្រឆាំងនឹងអ្នកកាសែតប្រឆាំង ឬអ្នកកាសែតឯករាជ្យ។ សមាជិករដ្ឋាភិបាលមិនខ្លាចនឹងប្ដឹងទៅតុលាការដើម្បីធ្វើការសងសឹកនឹងអ្នកកាសែតដែលបានសរសេរអត្ថបទរិះគន់ទេ។ បណ្ដឹងទាំងនេះនឹងធ្វើឲ្យអ្នកកាសែតអាចទទួលពិន័យបង់ប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ ឬទោសជាប់ពន្ធនាគារ។

ការធ្វើទុក្ខបុកម្នេញទៅលើសមាជិកក្រុមបក្សប្រឆាំង មេធាវី និងអ្នកកាសែតត្រូវបានប្ដឹងបរិហារដោយឧត្ដមស្នងការជាន់ខ្ពស់ផ្នែកសិទ្ធិមនុស្សនៅ ប្រទេសកម្ពុជា។ នៅក្នុងសេចក្ដីប្រកាសមួយនៅខែ ឧសភា ឆ្នាំ ២០០៩ អ្នកតំណាងរបស់អង្គការសហប្រជាជាតិមួយរូបបាននិយាយសង្កត់ធ្ងន់ថា៖«សកម្មភាពទាំងនេះគំរាមកំហែងទៅលើគោលការណ៍រដ្ឋធម្មនុញ្ញស្ដី ពីសេរីភាពបញ្ចេញមតិ»។ ជាមួយគ្នានោះ សារព័ត៌មានក្នុងស្រុកក៏ ចាប់ផ្ដើមភ័យខ្លួន ចំពោះការកើនឡើងនៃ ចំនួនបណ្ដឹងប្រឆាំងនឹងអ្នកកាសែតដែរ។ កាសែតបារាំង Le Cambodge Soir បានដាក់ចំណងជើងលើអត្ថបទរបស់ខ្លួនថា ៖ «តើគេនៅតែអាចរិះគន់រដ្ឋាភិបាលបានដែរឬទេ?» ចំណែកកាសែតជាភាសាអង់គ្លេស The Cambodia Daily បានចេញផ្សាយនូវបទវិចារណកថាប្រកាសអាសន្នជាច្រើនទៅលើរឿងនេះ។

លោកហ៊ុន សែនដែលកាន់អំណាចចាប់តាំងពីឆ្នាំ ១៩៨៥មក គឺជាមេដឹកនាំម្នាក់ដែលនៅបន្តកាន់អំណាចបានយូរជាងគេក្នុងពិភពលោក។ គណបក្សប្រជាជនមានសំលេងលើសលប់នៅក្នុងសភា ជាមួយនឹងអ្នកតំណាងរាស្ត្ររបស់ខ្លួនចំនួន ៩០រូប ចំណែកគណបក្សប្រឆាំងមានតែ២៩អសនៈតែប៉ុណ្ណោះ។ បណ្តាញព័ត៌មានជាច្រើនសរសេររឿងទាក់ទងនឹងលោកហ៊ុន សែនដោយសេចក្តីគោរព និងប្រើពាក្យ សេម្តច ដែលជាគោរម្យងាររបស់ព្រះរាជវាំង។ កំលាំងអំណាចធ្វើឲ្យមានការលំបាកក្នុងការធ្វើឲ្យមានលទ្ធិប្រជាធិបតេយ្យមួយ។ សេរីភាពសារព័ត៌មានដែលត្រូវតែពង្រឹងឡើង និងសិទ្ធិទទួលបានព័ត៌មានរឹតតែមានសារៈសំខាន់ដើម្បីជានាថារឿងរ៉ាវដែលកើតឡើងនៅក្នុងព្រះរាជាណាចក្រត្រូវបានគេដឹងលឺ។

ប្រធានក្លឹបអ្នកកាសែតកម្ពុជាលោក ប៉ែន សាមិទ្ធិបាននិយាយថា ៖ ជនជាតិថៃដែលត្រូវចោទប្រកាន់ពីបទធ្វើចារកម្ម បានទទួលព្រះរាជក្រិតលើកលែងទោសពីព្រះមហាក្សត្រតែក្នុងរយៈពេលប៉ុន្មានថ្ងៃ។ ចំណែកលោកហង្ស ចក្រាដែលកំពុងជាប់គុកឯណោះវិញ មិនបានទទួលប្រយោជន៍ពីវិធានការណ៍លើកលែងទោសនោះទេ។ គឺជាស្ថានភាពដ៏ធ្ងន់ធ្ងរមួយ។

ជាក់ស្តែង ហង្ស ចក្រាដែលជាចាងហ្វាងកាសែតខ្មែរម្ចាស់ស្រុកត្រូវបានគេចាប់ដាក់ឃុំ ចាប់តាំងពីថ្ងៃទី ២៦ មិថុនា ឆ្នាំ ២០០៩ បន្ទាប់ពីត្រូវបានតុលាការសម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ។ ទីស្តីការគណៈរដ្ឋមន្ត្រីជាអ្នកប្តឹងផ្ទាល់ ដោយប្រតិកម្មទៅលើអត្ថបទមួយដែលនិយាយពីភាពតានតឹងរវាងលោកហ៊ុន សែន និងបុរសខ្លាំងទី ២របស់រដ្ឋាភិបាល។ បន្ទាប់ពីធ្វើពាក្យបណ្តឹងរួចមក លោកចាងហ្វាងកាសែតត្រូវបានបញ្ជាឲ្យប្រាប់ប្រភពនៃអត្ថបទរបស់ខ្លួន។ ប៉ុន្តែលោកហង្ស ចក្រាបានបដិសេធ។

លោកឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលជាអ្នកទទួលខុសត្រូវទាំងស្រុងលើការដាប់ពន្ធនាគាររបស់អ្នកកាសែតហង្ស ចក្រា មិនសូវសប្បាយចិត្តប៉ុន្មាននឹងអត្ថបទរបស់កាសែតម្ចាស់ស្រុកដែលផ្សាយ នៅខែមេសា និងខែ ឧសភា។ អត្ថបទទាំងនោះនិយាយបើកកកាយពីសកម្មភាពពុករលួយដែលប្រព្រឹត្តដោយអ្នកសហការការងារជាមួយនឹងលោក សុខ អាន។

កាសែតបានដាក់ចំណងជើងថា ៖ ហ៊ុន សែនបានបំបែកសំបុកពុករលួយដែលជាក្រុមរបស់ពួកសុខ អាន។ អ្នកដែលស្និទ្ធនឹងលោក សុខ អានកំពុងប្រឈមមុខនឹងការបណ្តេញចេញតំណែង។

និយាយតាំងពីបន្ទប់ឃុំខ្លួនក្នុងគុកព្រៃស ដែលនៅទីនោះ លោកត្រូវគេដាក់ឃុំរួមជាមួយនឹងអ្នកទោស និងឧក្រិដ្ឋជន លោកហង្ស ចក្រាបាននិយាយការពារពីភាពគ្មានទោសរបស់លោក។ លោកបានធ្វើការបញ្ជាក់ថា ៖ «ករណីរបស់ខ្ញុំពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអត្ថបទដែលកាសែតរបស់យើងបានចុះផ្សាយ។ ទាំងនេះឆ្លុះបញ្ចាំងពីស្ថានភាពធ្លាក់ចុះនៃសេរីភាពសារព័ត៌មានដែលកាន់តែរួញតូចទៅៗនៅក្នុងប្រទេស។ ហេតុអ្វីបានជាគេមិនកាត់ទោសខ្ញុំដោយប្រើច្បាប់សារព័ត៌មាន? តើការកាត់ទោសពីបទផ្សាយព័ត៌មានមិនពិតមានន័យយ៉ាងម៉េចពិតប្រាកដ? វាអយុត្តិធម៌ និងខុសច្បាប់។ ប៉ុន្តែ ទោះយ៉ាងណា ខ្ញុំនឹងបន្តការតស៊ូរបស់ខ្ញុំទៅមុខទៀតដើម្បីសិទ្ធិសេរីភាពបញ្ចេញមតិ។

លោក ហង្ស ចក្រា ត្រូវឃុំខ្លួននៅក្នុងបន្ទប់ដែលមានអ្នកទោសចំនួន ៤៨ នាក់។

លោក បានត្អូញត្អែរពីស្ថានភាពដ៏អាក្រក់នៃការឃុំខ្លួនរបស់លោកថា៖ «រស់នៅក្នុងគុក គឺជារឿងមួយដ៏វេទនាជាទីបំផុត។ នៅក្នុងគុក មានការប្រឈមមុខដាក់គ្នា អំពើហឹង្សា និងការខ្វះចំណីអាហារដ៏ត្រឹមត្រូវ។ល។ ខ្ញុំធ្លាក់ខ្លួនចុះខ្សោយយ៉ាងរហ័ស។ សុខភាពរបស់អ្នកកាសែតរូបនេះបានធ្លាក់ចុះយ៉ាងរហ័ស។ គាត់មានជំងឺ លើស

ឈាម និង កើតរមាស់សើស្បែក។ កាលពីខែ ធ្នូ គាត់ធ្លាក់ខ្លួនឈឺជំងឺផ្ដាសាយ។ ជំងឺរលាកផ្លូវដង្ហើមដែលគាត់បានធ្លងនៅក្នុងពេលជាប់ឃុំលើកមុន ចាប់ផ្ដើមរើឡើងវិញ។

នៅពេលត្រូវបានសំភាសន៍ដោយអ្នកតំណាងរបស់អង្គការ អ្នកកាសែតគ្មានព្រំដែន កូនស្រីរបស់លោកហង្ស ចក្រា គឺកញ្ញា ហង្ស ចាន់ពិសី បានបង្ហាញពីការព្រួយបារម្ភរបស់ខ្លួន។ នាងពិសីបានរៀបរាប់ថា ៖ « ពួកយើងបានទៅសួរសុខទុក្ខគាត់ជាញឹកញាប់ និងតែងតែយកចំណីអាហារ និងថ្នាំពេទ្យទៅឲ្យគាត់។ បើទោះបីជាមានបញ្ញើទាំងអស់នោះ ក៏ផ្ទុយទៅវិញ សុខភាពរបស់គាត់កាន់តែដាបឡើងៗ»។ ចាន់ពិសី បានពន្យល់បន្ថែមថា ៖ «ពួកយើងបានសរសេរសំបុត្រទៅកាន់លោកឧបនាយករដ្ឋមន្ត្រី ប៉ុន្តែយើងមិនដែលបានទទួលចំលើយឆ្លើយតបមកវិញទេ។ វាជាការពិតដែលរដ្ឋមន្ត្រី ក្រសួងព័ត៌មានបានទទួលជួបពួកយើង និងគាំទ្រយើង ប៉ុន្តែ យើងមិនមានអារម្មណ៍ថា សំណើសុំព្រះរាជទានលើកលែងទោសត្រូវបានគេធ្វើឡើងពិតប្រាកដទេ»។

កាលពីខែ កញ្ញា អ្នកនាំពាក្យរបស់រដ្ឋាភិបាលម្នាក់បានទៅជួបអ្នកកាសែតហង្ស ចក្រាដល់ពន្ធនាគារ។ អ្នកនាំពាក្យរូបនោះបានសន្យាទៅអ្នកកាសែតថា នឹងជួយឲ្យមានការដោះលែងរូបលោក។ ប៉ុន្តែជាថ្នូរវិញ អ្នកកាសែតត្រូវចុះចូលជាមួយរដ្ឋាភិបាល។ សំណើនេះត្រូវបានលោកហង្ស ចក្រាបដិសេធ។

ជាមួយគ្នានោះ សហជីវិនរបស់លោកហង្ស ចក្រាដែលនៅបន្តចេញផ្សាយកាសែត កំពុងជួបប្រទះនឹងបញ្ហាហិរញ្ញវត្ថុជាចាំបាច់។ ពួកគេមានការព្រួយបារម្ភពីអនាគតរបស់កាសែតដែលមានជំហររិះគន់ក្នុងប្រទេសកម្ពុជា។ លោកជុំ សុផល ចាងហ្វាងស្ដីទីកាសែត ខ្មែរម្ចាស់ស្រុក ទទួលស្គាល់ថា កាសែតរបស់លោកបច្ចុប្បន្នធ្វើការរិះគន់តិចជាងមុន នោះគឺដោយខ្លាចគេពន្យារពេលដោះលែងលោកហង្ស

ចក្រា។ កាសែតខ្មែរម្ចាស់ស្រុកដែលមិនបានទទួលការផ្សព្វផ្សាយពាណិជ្ជកម្មមួយ សោះ ចេញផ្សាយចំនួន ៩០០ច្បាប់ក្នុងមួយថ្ងៃ។ លោក បោយ រើយ អ្នកយកព័ត៌មានម្នាក់ទៀតរបស់កាសែតខ្មែរម្ចាស់ស្រុក បាននិយាយថា៖ «ការចាប់ ដាក់គុក គឺ ជាមធ្យោបាយសម្រាប់បំបិទសំលេងរបស់ក្រុមអ្នកប្រឆាំង»។

សវនាការកាត់ក្តីប្រឆាំងទៅលើលោក ហង្ស ចក្រាដែលធ្វើឡើងដោយ ចៅក្រម ឌីន ស៊ីវុទ្ធី បានប្រព្រឹត្តឡើងក្នុងលក្ខណ្ឌមួយដ៏ខ្វះខាត។ មេធាវីរបស់លោក ហង្ស ចក្រា បានអះអាងប្រាប់អង្គការអ្នកយកពត៌មានគ្មានព្រំដែន ថា៖ «សាលាក្តី បានពន្លឿននីតិវិធីដើម្បីអាចផ្តល់នូវសាលក្រមឆាប់ៗ (Ö) ពេល គឺបើទោះជាមិន មានវត្តមានរបស់កូនក្តីរបស់ខ្ញុំ និងបន្ទាប់ពីបដិសេធសំណើរបស់ខ្ញុំដែលសុំលើកថ្ងៃ សវនាការ»។

ចាប់តាំងពីឆ្នាំ ២០០៨ មក វាជាលើកទីមួយដែលអ្នកកាសែតត្រូវគេ ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ។ កាលណោះ លោកដាំ សិទ្ធិដែលជាចាងហ្វាង កាសែតប្រចាំថ្ងៃ មនសិការខ្មែរ ដែលនៅពេលនេះបញ្ឈប់ការចេញផ្សាយរបស់ខ្លួន ត្រូវបានអាជ្ញាធរចាប់ដាក់គុកមួយសប្តាហ៍ បន្ទាប់ពីមានពាក្យបណ្តឹងពីរដ្ឋមន្ត្រី ក្រសួងការបរទេស។ រដ្ឋមន្ត្រីការបរទេសបានប្តឹងអ្នកកាសែតរូបនេះ ពីបទផ្សាយ ព័ត៌មានមិនពិត។ សម្រាប់លោក ហ្សង់ហ្វ្រង់ស័រ ដេសម៉ាហ្សីអ៊ែរ អគ្គរដ្ឋទូតបារាំង ប្រចាំកម្ពុជា ករណីរបស់លោក ហង្ស ចក្រាត្រូវតែគេលើកឡើងជាមួយអាជ្ញាធរ ពីព្រោះវាច្បាស់ណាស់ថា រឿងនេះជារឿងទាក់ទងនឹងសេរីភាពសារព័ត៌មាន។

បើតាមលោក ប៉ែន សមិទ្ធិ ប្រធានក្លឹបអ្នកកាសែតកម្ពុជា ការដាក់ទោសទៅ លើអ្នកកាសែតនឹងអាចកើនឡើង ប្រសិនបើមន្ត្រីរដ្ឋាភិបាល និងមន្ត្រីថ្នាក់មូលដ្ឋាន ប្រើប្រាស់អ្នកតំណាងច្បាប់របស់រដ្ឋាភិបាល (ឬមេធាវីរបស់រដ្ឋាភិបាល) ដើម្បី ធ្វើការប្តឹងផ្តល់។ លោក អ៊ុំ សារិន អ្នកទទួលខុសត្រូវរបស់សមាគមកម្ពុជាដើម្បី

ការពារអ្នកកាសែត (CAPJ) បានបញ្ជាក់ថា ៖ «ចៅក្រមមិនអាចទប់ទល់នឹងគំនាបសង្កត់ នៅពេលពាក្យបណ្តឹងចេញផ្ទាល់ពីរដ្ឋាភិបាល។ ប្រព័ន្ធតុលាការបានក្លាយជាអាវុធដ៏គ្រោះថ្នាក់ដែលមន្ត្រីពុករលួយមួយចំនួនបានប្រើប្រាស់ដើម្បីការពារខ្លួន និងចាកផុតពីការបរិហាររបស់អ្នកកាសែត។

## ក្រមព្រហ្មទណ្ឌថ្មី សេរីភាពថ្មី?

ប្រទេសកម្ពុជាបានសន្យាធ្វើកំណែទំរង់ទៅលើច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន។ បើទោះបីជាអត្ថបទច្បាប់នៅ មិនទាន់ត្រូវបានគេប្រកាសឲ្យប្រើប្រាស់ក្តី ប៉ុន្តែការកែប្រែដ៏ស៊ីជម្រៅដែលផ្តោតទៅលើប្រព័ន្ធច្បាប់ នឹងអាចផ្តល់ផលទៅលើសេរីភាពបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន។ ប៉ុន្តែ ការខ្វះតម្លាភាពនៅជុំវិញបញ្ហាសរសេរច្បាប់នៅដំណាក់កាលចុងក្រោយបានធ្វើឲ្យមានការព្រួយបារម្ភពីសំណាក់អ្នកកាសែត និងសកម្មជនការពារសិទ្ធិមនុស្ស។

ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ ១៩៩៥ បានចែងចំណុចជាច្រើនដែលការពារអ្នកយកព័ត៌មាន។ នៅក្នុងច្បាប់នោះ មានចែងពីការហាមឃាត់មិនឲ្យមានការត្រួតពិនិត្យមុនទៅលើអត្ថបទ និង សិទ្ធិនៃការរក្សាភាពសំងាត់នៃប្រភពផ្តល់ព័ត៌មាន (មាត្រាទី ២)។ ប៉ុន្តែ អត្ថបទច្បាប់នោះក៏ចែងផងដែរថា «សារព័ត៌មានមិនត្រូវចេញផ្សាយព័ត៌មានណាដែលធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថិរភាពនយោបាយ។ ច្បាប់សារព័ត៌មានបានហាមការផ្សព្វផ្សាយព័ត៌មានមិនពិតដែលអាចប៉ះពាល់ដល់ «កិត្តិយស និងសេចក្តីថ្លៃថ្នូរ។ នៅក្នុងខ្លឹមសារអត្ថបទនោះ ពាក្យដូចជា «សន្តិសុខជាតិ» «ស្ថិរភាពនយោបាយ» និង«កិត្តិយស និងសេចក្តីថ្លៃថ្នូរ មិនត្រូវបានកំណត់ច្បាស់លាស់ទេ។ ដូច្នេះ វាអាចជារឿងងាយបំផុតដែលគេប្រើច្បាប់នេះដើម្បីប្រឆាំងនឹងអ្នកសារព័ត៌មានវិញ។ ច្បាប់សារព័ត៌មានឆ្នាំ ១៩៩៥ បាន

ចែងថា ជនណាក៏ដោយដែលត្រូវខូចបង្ខូចឈ្មោះដោយប្រព័ន្ធព័ត៌មាន អាចទាមទារការសងជំងឺចិត្តក្នុងបណ្តឹងរដ្ឋប្បវេណី។

បើទោះបីជាច្បាប់នេះនៅមិនទាន់ត្រឹមត្រូវល្អឥតខ្ចោះ បើប្រៀបធៀបទៅនឹងខ្នាតអន្តរជាតិក្តី ប៉ុន្តែ ច្បាប់សារព័ត៌មាននេះទំនងជាបានការពារសេរីភាព និងបានជួយឲ្យចៀសផុតនូវការចាប់ដាក់គុកដែលបណ្តាលមកពីបទល្មើសក្នុងរឿងសារព័ត៌មាន។ ប៉ុន្តែ មេធាវីរបស់រដ្ឋាភិបាល ឬក៏ដើមបណ្តឹងឯកជនធ្វើមិនដឹងមិនលឺពីច្បាប់សារព័ត៌មាននេះ និងតែងតែយកច្បាប់ព្រហ្មទណ្ឌមកប្រើប្រាស់ដើម្បីប្តឹងអ្នកកាសែត។ ក្រមព្រហ្មទណ្ឌ ឬច្បាប់ព្រហ្មទណ្ឌរបស់អ៊ុនតាក់ ដែលបន្ទល់ពីបេសកកម្មរបស់អង្គការសហប្រជាជាតិ ចែងដាក់ពិន័យទៅលើការបង្ខូចកេរ្តិ៍ឈ្មោះ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់។ ប្រសិនបើមាត្រាទី ២០នៃច្បាប់អ៊ុនតាក់ ចែងថា គ្មានជនណាម្នាក់នឹងត្រូវគេចាប់ខ្លួន ឬចាប់ដាក់គុកដោយសារតែបានបញ្ចេញមតិ និងយោបល់របស់ខ្លួនទេ ក៏ប៉ុន្តែមាត្រាជាច្រើនដទៃទៀតនៃក្រមនេះបានកំណត់ឲ្យមានការផាកពិន័យជាប្រាក់ច្រើនគួរសម និងទោសជាប់ពន្ធនាគារសម្រាប់បទល្មើសធ្ងន់ធ្ងរ។ ដូច្នេះ ការផ្សាយព័ត៌មានមិនពិតមានកំណត់នៅក្នុងមាត្រា ទី ៦២។ គេអាចពិន័យឲ្យជាប់គុកជាអតិបរមា ៣ឆ្នាំចំពោះការផ្សាយព័ត៌មានមិនពិត ការច្នៃប្រឌិតព័ត៌មាន និង ការក្លែងព័ត៌មាន ឬផ្សាយព័ត៌មានណាដែលអាចគំរាមកំហែងដល់សន្តិភាពសាធារណៈ។

ខសំខាន់មួយទៀតរបស់ច្បាប់អ៊ុនតាក់ ដែលជួនកាលត្រូវគេបានប្រើប្រាស់ដើម្បីប្រឆាំងនឹងអ្នកកាសែត និងអ្នកប្រឆាំង គឺចែងពីបទញុះញង់។ មនុស្សម្នាក់អាចត្រូវចោទប្រកាន់ពីបទបង្កការញុះញង់ បើទោះបីជាមិនមានបទល្មើសត្រូវបានបង្កឡើងក្តី។

នៅខែ ឧសភា ២០០៦ ដោយឆ្លើយតបទៅនឹងសំណើរបស់អ្នកសារព័ត៌មាន និងសង្គមស៊ីវិល លោកហ៊ុន សែនបានប្រកាសថា ទោសជាប់គុកដោយសារតែការបរិហារកេរ្តិ៍គួរតែលុបចេញពីក្នុងច្បាប់។ ប៉ុន្តែទោះយ៉ាងណា បទល្មើសនោះនៅតែជាការជេរប្រមាថដែលនៅជាប់នឹងបទឧក្រិដ្ឋ។ នោះគឺមានន័យថា អ្នកកាសែតដែលកាត់ទោសពីបទបរិហារកេរ្តិ៍អាចនឹងត្រូវផ្តន្ទាទោសឲ្យជាប់គុក ប្រសិនបើពួកគេមិនអាចបង់ប្រាក់ពិន័យដែលកំណត់ដោយតុលាការទេនោះ។

លោកអ៊ុំ សារិន សកម្មជនដើម្បីសេរីភាពសារព័ត៌មាន បានសំដែងការសោកស្តាយថា ៖ «ការសម្រេចចិត្តរបស់នាយករដ្ឋមន្ត្រី ជារឿងល្អមួយ ប៉ុន្តែភ្លាមៗ សមាជិករបស់រដ្ឋាភិបាលមួយចំនួនបានប្រើប្រាស់បទចោទប្រកាន់ផ្សព្វផ្សាយព័ត៌មានមិនពិតដើម្បីជៀសវាងកុំឲ្យអ្នកកាសែតអាចទទួលផលពីភាពមិនអាចដាក់ទោស។ មិនទាន់មានអ្នកណាម្នាក់ហ៊ានអះអាងថា ក្រមព្រហ្មទណ្ឌថ្មីនឹងជួយដោះស្រាយបញ្ហានេះបាននោះទេ។ លើសពីនោះទៀត សមាជិកសភាមកពីគណបក្សប្រឆាំងមិនបានមានវត្តមាននៅក្នុងការប្រជុំរបស់គណៈកម្មាការដែលពិភាក្សាស្តីពីអត្ថបទច្បាប់នោះទេ។

ដោយសារតែក្តីព្រួយបារម្ភមានកាន់តែច្រើន រដ្ឋមន្ត្រីក្រសួងព័ត៌មានព្យាយាមធ្វើការធានាមួយ។ លោកបានអះអាងថា ៖ «ច្បាប់សារព័ត៌មានមានខ្លឹមសារល្អ ហើយប្រសិនបើ អ្នកកាសែតមានមេធាវីល្អទៀត នោះគឺអ្នកកាសែតអាចចាកផុតពីការចោទប្រកាន់បាន។ ក្រមព្រហ្មទណ្ឌថ្មីនឹងរឹតតែប្រសើរជាងនេះទៅទៀត។ ម្យ៉ាងទៀត សមាជិករបស់រដ្ឋាភិបាលភាគច្រើនបានយល់ព្រមមិនប្រើប្រាស់ក្រមព្រហ្មទណ្ឌថ្មី នៅក្នុងរឿងក្តីទាក់ទងនឹងសារព័ត៌មាន។

ការងារសរសេរក្រមព្រហ្មទណ្ឌថ្មីត្រូវបានជួយគាំទ្រដោយសហប្រតិបត្តិការបារាំង។ ការសរសេរច្បាប់ថ្មីនេះផ្អែកទៅលើប្រព័ន្ធ Romano Germanique ក្នុង

បំណង់គ្រប់គ្រងឲ្យបានប្រសើរនូវការងាររបស់ចៅក្រម។ បើតាមសេចក្ដីកត់ត្រាបែបវិភាគដែលធ្វើឡើងដោយអ្នកស្រាវជ្រាវបារាំងម្នាក់ ដើម្បីអាចការពារមិនឲ្យមានការរំលោភបំពាន និងលូកដៃរបស់អំណាចប្រតិបត្តិចូលមកក្នុងប្រព័ន្ធតុលាការ និងដើម្បីធ្វើឲ្យប្រសើរឡើងនូវឯករាជ្យភាពរបស់តុលាការ គេគួរគ្រប់គ្រងការងាររបស់មន្ត្រីតុលាការឲ្យបានម៉ត់ចត់បំផុត។ មែនទែនទៅ មេធាវីរបស់រដ្ឋាភិបាលឈ្នះជាស្វ័យប្រវត្តិក្នុងរឿងក្ដីដែលពួកគេបង្កឡើង។ ជាមួយគ្នានោះ អំពើពុករលួយនៅក្នុងតុលាការត្រូវបានគេរិះគន់ជាច្រើនពាន់ដង។

នៅក្នុងអត្ថបទច្បាប់ថ្មីនេះ តួអង្គព្រះមហាក្សត្រដែលត្រូវបានការពាររួចហើយនៅក្នុងមាត្រាទី ៧ និងទី៨របស់ច្បាប់រដ្ឋធម្មនុញ្ញ និងមិនត្រូវគេយកមកធ្វើជាប្រធានបទនៃការពិភាក្សា ឬរិះគន់ទេ។ នៅអត្ថបទច្បាប់ដើម ការបរិហារកេរ្តិ៍ និងការជេរប្រមាថនឹងមិនត្រូវទទួលទោសជាប់ពន្ធនាគារឡើយ។ ភាពគ្មានទោសពៃដោយសារបានប្រព្រឹត្តបទល្មើសក្នុងវិស័យសារព័ត៌មានបានធ្វើឲ្យច្បាប់នេះ មានភាពស្របគ្នាជាមួយនឹងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣បានច្បិចយកគោលការណ៍មួយចំនួនរបស់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ដែលចែងថា ពលរដ្ឋកម្ពុជាមានសិទ្ធិនិយាយ សរសេរ បោះពុម្ព។ តាមរយៈកាសែត ឬតាមមធ្យោបាយអ្វីផ្សេងទៀត ពួកគេមានសិទ្ធិបញ្ចេញមតិ ផ្សព្វផ្សាយ ការពាររាល់មតិយោបល់ក្នុងលក្ខណ្ឌដែលគេមិនត្រូវប្រើសិទ្ធិឲ្យជ្រុលហួសហេតុ និងក្នុងលក្ខណ្ឌដែលគេមិនមានបំណងធ្វើឲ្យខូចសណ្ដាប់ធ្នាប់សាធារណៈ(មាត្រាទី៩)។

នៅពេលដែលសកម្មជនតស៊ូដើម្បីសេរីភាពបញ្ចេញមតិ សង្ឃឹមថាបទល្មើសទាក់ទងដោយផ្ទាល់ ឬដោយប្រយោលនឹងត្រូវគេកាត់បន្ថយតាមរយៈក្រមព្រហ្មទណ្ឌថ្មីនេះ ស្រាប់តែមានបទចោទប្រកាន់ថ្មីៗត្រូវបានគេបញ្ចូលទៅក្នុងច្បាប់ព្រហ្មទណ្ឌដែលមានដូចជា ការផ្សាយព័ត៌មានខុស (មាត្រាទី៤២៨) ការជេរប្រមាថជាសាធារណៈ (មាត្រា ទី ៣០៧) ការបរិហារដែលធ្វើឲ្យប៉ះពាល់ដល់

*កិត្តិយសា (មាត្រាទី៣១១) ឬការធ្វើបោះពុម្ពនូវបទអត្ថាធិប្បាយក្នុងន័យដាក់គំនាបទៅលើប្រព័ន្ធច្បាប់ា (មាត្រា ទី ៥២៣)។ អ្នកដែលត្រូវចោទប្រកាន់ក្នុងបទល្មើសទាំងនេះ នឹងត្រូវផ្តន្ទាទោសឲ្យជាប់គុក។ ប៉ុន្តែ ម្ចាស់សំណេរច្បាប់ បានបង្ហាញថាបទល្មើសទាំងនេះនឹងពាក់ព័ន្ធទៅនឹងសេរីភាពបញ្ចេញមតិទេ។*

*នៅក្នុងខ្លឹមសារអត្ថបទព្រាងរបស់ក្រមព្រហ្មទណ្ឌថ្មីដែលអង្គការអ្នករាយការណ៍គ្មានព្រំដែនបានទទួល គេបានបញ្ជាក់នៅក្នុងមាត្រាទី ៣០៦ថា ការបរិហារកេរ្តិ៍ ការជេរប្រមាថក្នុងកាសែត ត្រូវគេយកមកដោះស្រាយដោយប្រើច្បាប់សារព័ត៌មាន។ ប៉ុន្តែ តើមេធាវីរបស់រដ្ឋាភិបាល ព្រះរាជអាជ្ញារ និងចៅក្រមគោរពទៅតាមការចែងនេះដែរឬទេ? ដូច្នេះ អំណើះតទៅ ច្បាប់ថ្មីនេះអាចនឹងត្រូវគេផ្លាស់ប្ដូរ និងយកទៅប្រើប្រាស់ដើម្បីបំបាត់សំលេង និងប្រព័ន្ធផ្សព្វផ្សាយដែលមានលក្ខណ:រិះគន់ដែរឬយ៉ាងណា?*

*ស្ថានទូតបារាំងប្រចាំនៅកម្ពុជាបានធ្វើការជានាអះអាង និងរំលឹកថាគម្រោងច្បាប់នេះបានដកស្រង់ពីគោលការណ៍ដើម្បីការពារប្រជាធិបតេយ្យ។ ប៉ុន្តែ នៅត្រង់ថា គេប្រើវាឲ្យបានត្រឹមត្រូវ តាមច្បាប់របស់រដ្ឋឬអត់ គឺអាស្រ័យទៅលើការផ្លាស់ប្ដូរចុងក្រោយដែលគណបក្សកាន់អំណាចចង់បាន។*

*នៅក្នុងក្របខ័ណ្ឌនៃច្បាប់ តើអ្នកយកព័ត៌មាននឹងអាចនិយាយពីប្រធានបទដែលរសើប ដូចជា រឿងពុករលួយរបស់ពួកអ្នកធំ និងរឿងរកស៊ីរបស់សហគ្រាសធំៗ បានយ៉ាងដូចម្ដេច?* Stephanie Gee *អ្នកយកព័ត៌មានសម្រាប់កាសែតបារាំងប្រចាំកម្ពុជាបានបញ្ជាក់ថា ៖ ៲បណ្ដឹងជាបន្ដបន្ទាប់ និងថ្មីៗនេះរឹតតែធ្វើឲ្យអ្នកកាសែតក្នុងស្រុកមិនហ៊ានផ្ដល់ឈ្មោះជនសង្ស័យដែលពាក់ព័ន្ធនឹងអំពើពុករលួយ ឬការកាប់ព្រៃឈើនៅក្នុងអត្ថបទស៊ើបអង្កេតរបស់ពួកគេ។ បញ្ហាទាំងនេះកំពុងកើតឡើងកាន់តែច្រើននៅតាមខេត្ត។*

ការភ័យខ្លាចនឹងការជាប់គុកច្រវាក់បានធ្វើឲ្យអ្នកកាសែតរឹតតែធ្វើការកម្រិតលើខ្លួនឯងក្នុងការសរសេរព័ត៌មាន។ ព័ត៌មានដែលអាចធ្វើឲ្យខ្លួនគេទទួលគ្រោះថ្នាក់ដូចជា បញ្ហាទំនាក់ទំនងជាប្រទេសជិតខាងវៀតណាម ឬវត្តមានរបស់ក្រុមទាហានទៅក្នុងការងាររបស់រដ្ឋាភិបាល និងសេដ្ឋកិច្ច។

## ទិដ្ឋភាពនៃបណ្តាញផ្សព្វផ្សាយដែលភាគច្រើនត្រូវបិទបង្ខាំង

គ្រប់ទូរទស្សន៍គ្រប់គ្រងទាំងស្រុងដោយគណបក្សកាន់អំណាច និងគ្រួសាររបស់លោកហ៊ុន សែន ប៉ុន្តែលើកលែងតែទូរទស្សន៍CTNដែលគ្រប់គ្រងដោយអ្នកជំនួញម្នាក់។ គង់ សុឋានរិទ្ធិ អ្នកកាសែតរបស់វិទ្យុសំលេងសហរដ្ឋអាមេរិកបានពន្យល់ថា៖ ៅនៅក្នុងប្រធានបទសង្គម និងអំពើពុករលួយមួយចំនួន ទូរទស្សន៍ CTNហ៊ានលើកយកនិយាយ និងរិះគន់។ វាជារឿងគួរឲ្យលើកទឹកចិត្តខ្លាំងណាស់ ក៏ប៉ុន្តែ ការរិះគន់នោះនៅមានកំរិតមនៃទៀត។ ចំណែក ទូរទស្សន៍រដ្ឋដូចជា TVK ត្រូវបានធ្វើឲ្យទំនើបជាងមុន ដោយសារជំនួយបរទេស។

អ្នកកាសែតបរទេសម្នាក់ដែលធ្វើការ នៅប្រទេសកម្ពុជាបាននិយាយបញ្ជាក់ថា៖ ៅនៅទីបំផុត គឺ ទូរទស្សន៍ដែលគ្រប់គ្រងដោយគ្រួសារ និងមិត្តភក្តិរបស់លោកហ៊ុន សែន ជាពិសេស គឺទូរទស្សន៍ អប្សារា ដែលត្រូវបានត្រួតពិនិត្យយ៉ាងល្អិតល្អន់បំផុតក្នុងរឿងដែលពាក់ព័ន្ធនយោបាយ។ នៅក្នុងទូរទស្សន៍ទាំងនោះ មិនមាននិយាយពីព័ត៌មានបែបរិះគន់ និងស៊ីជម្រៅទេ។

រដ្ឋមន្ត្រី ក្រសួងព័ត៌មានបានបង្ហាញពីកិច្ចប្រឹងប្រែងក្នុងការបោះជំហានទៅមុខ។ លោកបានមានប្រសាសន៍ថា ៖ ៅជាមួយនឹងអង្គការយូនេស្កូ យើងបានធ្វើ

កម្មវិធីសមធម៌មួយដើម្បីផ្តល់ឱកាសដល់អង្គការសង្គមស៊ីវិល។ ជាមួយគ្នានោះ យើងបានចាក់ផ្សាយកិច្ចពិភាក្សានៅក្នុងរដ្ឋសភា នៅតាមកញ្ចក់ទូរទស្សន៍រដ្ឋ។

លោកគឹម សុខា អ្នកតំណាងរាស្ត្រម្នាក់បាននិយាយផ្ទុយទៅវិញថា ៖ «កម្មវិធីសមធម៌ និយាយពីពួកយើងម្តងម្កាល ហើយទូរទស្សន៍ជាតិដទៃទៀតមិនដែលនិយាយពីពួកយើងទាល់តែសោះ។ វាជាការធ្វើពហិការមួយដែលបញ្ជាមកពីថ្នាក់លើ។ តើយើងអភិវឌ្ឍន៍ គំនិតបញ្ញារបស់យើងដោយរបៀបណា កាលបើរដ្ឋាភិបាលធ្វើរបៀបនេះ»។ អ្នកទទួលខុសត្រូវរបស់អង្គការលីកាដូបានបញ្ជាក់បន្ថែមថា៖ «បទអន្តរាគមន៍សំខាន់ៗរបស់គណបក្សប្រឆាំងត្រូវគេកាត់ចោល ក្នុងដំណាក់កាលនៃការកាត់តរូបភាព»។

សារព័ត៌មានដែលមានទំនោរគាំទ្ររដ្ឋាភិបាលជាអ្នកដឹកនាំមុខគេនៅក្នុងចំណោមកាសែតក្នុងប្រទេសកម្ពុជា។ បើទោះបីជាសារព័ត៌មានចំនួន ៣០០បានចុះបញ្ជីនៅក្រសួងព័ត៌មាន មានតែសារព័ត៌មានជាង៣០ប៉ុណ្ណោះដែលចេញការផ្សាយរបស់ខ្លួនជាទៀងទាត់។ កាសែតប្រឆាំង ប្រចាំថ្ងៃជាច្រើនមួយចំនួនបានទទួលគាំទ្រហិរញ្ញវត្ថុពីគណបក្សសម រង្ស៊ី បានឈប់ចេញផ្សាយ។ ឧទាហរណ៍ កាសែតមនសិការខ្មែរបានបិទទ្វាររបស់ខ្លួន នៅឆ្នាំ ២០០៩ បន្ទាប់ពីអាជ្ញាធរគំរាមថានឹងប្តឹងចាងហ្វាងកាសែត លោកដាំ សិទ្ធពីបទបរិហារកេរ្តិ៍។ ឆ្លើយនឹងសំណួររបស់អង្គការអ្នកយកពត៌មានគ្មានព្រំដែន លោកដាំ សិទ្ធបាននិយាយថា ៖ «ខ្ញុំបានសម្រេចចិត្តឈប់ចេញផ្សាយ ព្រោះមេធាវីរបស់រដ្ឋាភិបាលបានដាក់ពាក្យបណ្តឹងប្តឹងខ្ញុំ ក្នុងរឿងដែលខ្ញុំចេញផ្សាយអត្ថបទចំនួន ១៨ដែលនិយាយពីបញ្ហាផ្ទៃក្នុងរបស់គណបក្សប្រជាជន។ ខ្ញុំបានសម្រេចចិត្តធ្វើការសុំទោសដល់លោកហ៊ុន សែន និងផ្អាកការផ្សាយ។ បន្ទាប់ពីនោះ គេបានដកពាក្យបណ្តឹងវិញ (...) កាសែតប្រឆាំងបានបាត់ខ្លួនម្តងមួយ ម្តងមួយ ពីព្រោះអ្នកនយោបាយបានប្រើប្រាស់តុលាការដើម្បីគំរាមពួកគេ»។

ចំណែកចាងហ្វាងកាសែតសំលេងយុវជនខ្មែរបានផ្លាស់ប្តូរជំហររបស់ខ្លួន នៅមុនការបោះឆ្នោតជាតិ ឆ្នាំ ២០០៨។ ចាប់តាំងពីពេលនោះមក គាត់បានក្លាយជាអនុរដ្ឋលេខាធិការក្រសួងព័ត៌មាន។ ដូចគ្នានេះដែរ លោកថាច់ កេត ចាងហ្វាងកាសែតប្រឆាំងមួយទៀត បានទទួលតំណែងនៅក្រសួងព័ត៌មានបន្ទាប់ពីចុះចូលជាមួយគណបក្សកាន់អំណាច។

គណបក្សប្រឆាំងបានស្ងាប់បន្តិចម្តងៗ ពីព្រោះ កាសែតទាំងនេះរងការធ្វើពហិការពីម្ចាស់ផ្សាយពាណិជ្ជកម្ម។ នៅក្នុងឧទាហរណ៍មួយ គ្រូលក់ថ្នាំបុរាណម្នាក់បានរងការចុះត្រួតពិនិត្យពន្ធដារដោយមិនព្រាងទុកមួយ បន្ទាប់ពីគាត់ធ្វើការផ្សាយពាណិជ្ជកម្មនៅក្នុងកាសែតប្រឆាំង។ អ្នកទទួលខុសត្រូវរបស់អង្គការអ្នកកាសែតមួយដែលនិយាយក្នុងលក្ខ័ណ្ឌមិនបញ្ចេញឈ្មោះ បានបញ្ជាក់ថា ៖ «ពិតជាមានអារម្មណ៍ភ័យខ្លាច និងព្រឺខ្លង នៅក្នុងចំណោមអ្នកកាសែតប្រឆាំង។ ឧទាហរណ៍ពួកគេមិនដាក់ឈ្មោះរបស់ពួកគេនៅក្រោមអត្ថបទទេ។ ការភ័យខ្លាចទាំងអស់នេះពាក់ព័ន្ធទៅនឹងការចាប់ខ្លួន និងការបាញ់សំលាប់ទៅលើអ្នកកាសែតនៅក្នុងអតីតកាល»។

កាសែតរស្មីកម្ពុជា ដែលជាកាសែតប្រចាំថ្ងៃដ៏ធំមួយ សរសេរជាទៀងទាត់ពីប្រតិកម្មរបស់គណបក្សប្រឆាំងទៅលើរឿងរ៉ាវដែលកើតឡើង នៅថ្នាក់ជាតិ។ ការនេះបានបង្ហាញឲ្យឃើញពីការវិវត្តនៃសេចក្តីក្លាហានមួយ។ លោកប៉ែន សមិទ្ធី និពន្ធនាយកកាសែតរស្មីកម្ពុជា បាននិយាយថា ៖ «ខ្ញុំទទួលបានការស្នើសុំឲ្យមានសេចក្តីកែតម្រូវ ច្រើនជាងការគំរាមកំហែងប្តឹង។ កាលពីឆ្នាំ ២០០៩ មន្ត្រីម្នាក់បានប្រកាសថា គាត់នឹងប្តឹងពួកយើងដែលចុះផ្សាយអត្ថបទទាក់ទងនឹងការដាក់គោលបង្គោលភ្លើងនៅប្រាសាទអង្គរ។ យើងបានចេញមុខការពារខ្លួនតែឯកឯង ហើយបន្ទាប់មក បណ្តឹងនោះត្រូវបានគេទៅវិញ»។

អ្នកកាសែតមួយចំនួន ដូចជាលោកសយ សុភាពជាដើមដែលជាប្រធានកាសែត និងជាតារាបស់ទូរទស្សន៍ CTN និយាយលើកសរសើរពីការវិវត្តទៅមុខក្នុងផ្នែកវិជ្ជាជីវៈ និងទំនើបកម្មរបស់សារព័ត៌មានៗ ទាំងនោះគឺបានមកពីបរិយាកាសល្អដែលរដ្ឋាភិបាលបានផ្តល់ឲ្យ។ ស្ថាបនិករបស់មជ្ឈមណ្ឌល ព័ត៌មាន DAP បាននិយាយថា ៖៉គណបក្សសម រង្ស៊ីបានបន្ទោសយើងថា គាំទ្រលោកហ៊ុន សែន ប៉ុន្តែជាមួយគ្នានោះ គណបក្សបានធ្វើពហិការមិនទាក់ទងយើង។

នៅក្នុងបរិបទនេះ អ្នកទទួលខុសត្រូវកាសែតបរទេសក្នុងស្រុក ជាភាសាបារាំង និងអង់គ្លេស (ខាំបូឌៀ ដេលី ភ្នំពេញប៉ុស្ត កាបូដស័រ) អះអាងថា ខ្លួនមិនបានប្រឈមមុខនឹងការលំបាកដើម្បីធ្វើអត្ថបទសំខាន់ៗនោះទេ។ អ្នកកាសែតជនជាតិអង់គ្លេសម្នាក់និយាយថា ៖៉គំនាបទាំងឡាយធ្វើឡើងតែទៅលើអ្នកកាសែតជនជាតិខ្មែរដែលបំរើការឲ្យកាសែតរបស់យើង។ អ្នកកាសែតរួមការងាររបស់ខ្ញុំមួយចំនួនបានបដិសេធមិនធ្វើការស៊ើបអង្កេតទៅលើរឿងមួយចំនួន។ ពួកគេខ្លាចថាការស៊ើបអង្កេតនឹងអាចឈានទៅដល់ការប្តឹងពួកគេពីបទបរិហាកេរ្តិ៍។

លោកJÈrÙme MorniËre ចាងហ្វាងកាសែតបារាំង កាំបូដស័រ បានបញ្ជាក់ថា ៖៉វត្តមានកាសែតរបស់យើង គឺជាអ្វីដែលរដ្ឋាភិបាលត្រូវការដើម្បីបង្ហាញថា របបខ្លួនគោរពលទ្ធិប្រជាធិបតេយ្យ។ ប៉ុន្តែ យើងត្រូវទទួលស្គាល់ថា កាសែតរបស់យើងមិនមានការលំបាក និងព្រួយបារម្ភក្នុងការសរសេររឿង ដូចដែលកាសែតខ្មែរក្នុងស្រុកជួបប្រទះទេ។

វិទ្យុមួយចំនួនមានជំហរប្រឆាំងនឹងរដ្ឋាភិបាលបច្ចុប្បន្ន។ លោក ម៉មសូណាដូ ប្រធានវិទ្យុសំបុកឃ្មុំបាននិយាយថា៖ ៉រដ្ឋាភិបាលមានការសោកស្តាយដែលបានផ្តល់អាជ្ញាប័ត្របើកវិទ្យុដល់ខ្ញុំ។ ពួកគេបានព្យាយាមដាក់គំនាបដើម្បីឲ្យខ្ញុំ

សុខចិត្តបោះបង់ចោលការប្រឆាំងរបស់ខ្ញុំ។ ប៉ុន្តែ វត្តមានរបស់វិទ្យុសំបុកឃ្មុំគឺសំខាន់ណាស់សម្រាប់សេរីភាពបញ្ចេញមតិ។

វិទ្យុសំបុកឃ្មុំ (១០៥ FM) ជួលម៉ោងវិទ្យុរបស់ខ្លួនទៅឲ្យអង្គការស៊ីវិល និងគណបក្សប្រឆាំង។ ប៉ុន្តែអ្នកគ្រប់គ្រងអំណាចអាចមានប្រតិកម្មខ្លាំងៗ ប្រសិនបើវិទ្យុក្នុងស្រុកបប្រើសិទ្ធិរបស់ខ្លួនច្រើនពេក។ កាលពីឆ្នាំ ២០០៨ នៅក្នុងកំឡុងពេលយុទ្ធនាការបោះឆ្នោត វិទ្យុអង្គរ រដ្ឋា នៅក្នុងខេត្តក្រចេះត្រូវបានបញ្ជាឲ្យបិទផ្អាកបន្ទាប់ពីវិទ្យុនេះជួលម៉ោងដល់គណបក្សប្រឆាំង។

ការចាក់ផ្សាយតាមរលកធាតុអាកាសរបស់វិទ្យុអន្តរជាតិជាច្រើនក៏ជាកត្តាជានាមួយសម្រាប់ការទទួលដឹងព័ត៌មានឯករាជ្យ។ ជាឧទាហរណ៍ វិទ្យុបារាំងអន្តរជាតិបានចាក់ផ្សាយនៅតាមរលកធាតុអាកាស ២ គឺ FM១០២ និង FM៩២ (វិទ្យុបារាំងអន្តរជាតិ RFIបានទទួលអាជ្ញាប័ណ្ណ)។ វិទ្យុដែលមានមូលដ្ឋាននៅទីក្រុងប៉ារីស មានអ្នកឆ្លើយឆ្លងប្រចាំកម្ពុជា ចំនួន ៧នាក់។ លោក ហ្សង់ហ្វ្រង់ស័រ តាន់ អ្នកទទួលខុសត្រូវផ្នែកខ្មែរនៅវិទ្យុRFIបានពន្យល់ថា ៖ ìRFIបានទទួលអាជ្ញាប័ណ្ណដើម្បីដំឡើងអង់តែនផ្សាយបន្ត នៅដើមឆ្នាំ ១៩៩០។ ប៉ុន្តែ ទើបតែនៅ ឆ្នាំ ២០០៥ ទើបកម្មវិធីភាសាខ្មែរ ត្រូវបានផ្សព្វផ្សាយ។ គឺលោកហ៊ុន សែនផ្ទាល់ដែលបានផ្តល់ការអនុញ្ញាត។

ក្នុងករណីរបស់ខ្លួន វិទ្យុសំលេងសហរដ្ឋអាមេរិក VOAមានអ្នកធ្វើការនៅក្នុងប្រទេសកម្ពុជា ចំនួន ៨នាក់។ ចំណែក វិទ្យុ អាស៊ី សេរី មានអ្នកបំរើការ ជាង ២០ នាក់។ ឆ្លើយតបនឹងសំណួររបស់អង្គការអ្នកយកពត៌មានគ្មានព្រំដែន អ្នកឆ្លើយឆ្លងរបស់វិទ្យុ RFI RFA និងVOAបាននិយាយថា ពួកគេមិនមានការលំបាកក្នុងការស្វែងរក និងសរសេរព័ត៌មានទេ។ អ្នកកាសែតរបស់វិទ្យុបារាំងអន្តរជាតិម្នាក់បាននិយាយថា ៖ ìជាការពិត ឈ្មោះជាអ្នកកាសែតសម្រាប់វិទ្យុបរទេស បានការពារពួក

យើង។ ប៉ុន្តែ ការដែលកម្មវិធីរបស់យើងទទួលបានអ្នកស្តាប់កម្ពុជារាប់លាននាក់ គឺជារឿងមួយដែលគួរឲ្យលើកទឹកចិត្ត។

ឆ្លើយតបនឹងសំណួររបស់អង្គការអ្នកកាសែតគ្មានព្រំដែន រដ្ឋមន្ត្រីក្រសួងព័ត៌មានបានប្រកាសប្រាប់ថា រលកជាតុអាកាស FMនៅក្នុងរាជធានី ច្រើនហួសកំរិត ដូច្នេះ ក្រសួងពិបាកនឹងផ្តល់អាជ្ញាប័ត្រថ្មីទៅអ្នកចង់បង្កើតវិទ្យុ។ លោកខៀវ កញ្ញារិទ្ធិបានបញ្ជាក់ថា ៖ យើងមានអង់តែន ទូរទស្សន៍ ១១ និងអង់តែនវិទ្យុជាង ៤០ ដែលនៅក្នុងនោះ មាន៣០អង់តែនត្រូវបានដំឡើងនៅទីក្រុងភ្នំពេញ។ ចំនួនដ៏ច្រើននេះអាចធ្វើឲ្យរលកជាតុអាកាសឡើងណែនតឹង។ ហើយ យើងមិនបានដាក់គំនាបមិនឲ្យមានការធ្វើអាជ្ញាប័ត្រជាថ្មីទេ។ ផ្ទុយទៅវិញ គឺគណបក្សប្រឆាំងទេដែលជួលម៉ោងវិទ្យុធ្វើកម្មវិធីដើម្បីវាយប្រហារយើង។

រដ្ឋាភិបាលបានបដិសេធមិនផ្តល់អាជ្ញាប័ត្រវិទ្យុ ឬទូរទស្សន៍ដល់អ្នកដែលជំនិត ឬមាននិន្នាការគាំទ្រគណបក្សប្រឆាំង។ ឧទាហរណ៍ នៅឆ្នាំ ២០០៦ លោកម៉ម សូណង់ដូរបានទទួលចំលើយអវិជ្ជមានទៅនឹងសំណើរបស់លោកក្នុងការបន្ថែមកម្រិតផ្សាយទៅតាមខេត្ត។ លោក ម៉ម សូណង់ដូរបានបញ្ជាក់ថា ៖ ក្រសួងព័ត៌មានផ្តល់អាជ្ញាប័ត្រទៅតែអ្នកដែលស្និទនឹងអ្នកកាន់អំណាចដើម្បីធ្វើឲ្យណែនកម្រិតរលកជាតុអាកាសFM។ រហូតមកដល់ពេលនេះ គណបក្សប្រឆាំង សម រង្ស៊ី នៅតែមិនអាចទទួលសិទ្ធិបើកទូរទស្សន៍មួយសោះ។ ផ្ទុយទៅវិញ អ្នកកាសែត សយ សុភាព ដែលស្និទនឹងប្រមុខដឹកនាំរដ្ឋាភិបាល បានទទួលអាជ្ញាប័ត្របង្កើតវិទ្យុ នៅឆ្នាំ ២០០៩។

បណ្តាញព័ត៌មានមានការវិវត្តន៍ច្រើននៅតាមអាំងទែណែត។ គេហទំព័ររបស់វិទ្យុអន្តរជាតិដូចជាRFA កំពុងប្រកួតប្រជែងជាមួយនឹងគេហទំព័រក្នុងស្រុកជាពិសេស សារព័ត៌មានដើមអំពិលជាដើម ដែលគ្រប់គ្រងដោយលោកសយ

សុភាព និង Cambodia Express News (www.cen.com.kh)។ កាសែតដែលនៅក្រៅស្រុកបានបង្កើត Free Press Magazine (www.fpmonline.net) ដើម្បីផ្តល់ព័ត៌មានពេញលេញ ពីគ្រប់ភាគី និងឯករាជ្យ។ ចំណែក គណបក្សប្រឆាំងបញ្ចេញមតិរបស់ខ្លួននៅលើគេហទំព័ររបស់ខ្លួន គឺ Ki-media.blogspot.com

## ការងារមិនទៀងទាត់ និងអំពើពុករលួយបានធ្វើឲ្យវិជ្ជាជីវៈអ្នកកាសែតធ្លាក់ចុះ

លក្ខខណ្ឌសេដ្ឋកិច្ច សង្គមរបស់អ្នកកាសែតខ្មែរភាគច្រើន និង ការអនុវត្តនូវអំពើពុករលួយបានធ្វើឲ្យអ្នកដែលធ្វើការនៅក្នុងបណ្តាញផ្សព្វផ្សាយមានលក្ខ័ណ្ឌការងារច្បាស់លាស់។

ប្រាក់ខែដ៏ស្តួចស្តើង ការអនុវត្តស្រោមសំបុត្រ ថ្នូរ អំពើពុករលួយដោយផ្ទាល់ និងមិនផ្ទាល់។ រឿងទាំងអស់នេះ បានកើតឡើងចំពោះអ្នកកាសែតខ្មែរ ក៏ដូចជាអ្នកកាសែតក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដ៏ច្រើនដទៃទៀត។ ចំនួនផ្សាយពាណិជ្ជកម្មដ៏តិចតួច និងចំនួនជាវកាសែតនៅមានកំណត់ដោយសារអនក្ខរកម្មរបស់ប្រជាជនមិនបានធ្វើឲ្យកាសែតបានទទួលចំនូលគ្រប់គ្រាន់ដើម្បីអាចផ្តល់ប្រាក់ខែសមរម្យដល់បុគ្គលិករបស់ខ្លួន។

លោកគង់ សុឋានរិទ្ធ បានពន្យល់ថា ៖ អ្នកគ្រប់គ្រងកាសែតចាត់ទុកអ្នកកាសែតដូចជាអ្នកធ្វើការដោយកំលាំង តែមិនមែនជាបញ្ញាវន្តនោះទេ។ មានតែកាសែតបរទេសក្នុងស្រុកមួយចំនួនដូចជាកាសែតបាយ័ង និងអង់គ្លេសដែលអាចផ្តល់ប្រាក់ខែគួរសមមួយ។ ក្រៅពីនោះ អ្នកកាសែតមិនមានកិច្ចសន្យាការងារ មិនមានពេលសម្រាកដោយបានប្រាក់ខែ និងបានទទួលប្រាក់កម្រៃតិច។

លោក ប៉ែន សមិទ្ធីបានបញ្ជាក់បន្ថែម ៖ អ្នកកាសែតជាច្រើនមិនមានប្រាក់សន្សំផ្ទាល់ខ្លួនទាល់តែសោះ។ ការនេះបានធ្វើឲ្យពួកគេស្ថិតនៅស្ថានភាពខ្វះខាតហិរញ្ញវត្ថុ នៅចំពោះមុខមន្ត្រី និងម្ចាស់ក្រុមហ៊ុន។ ពួកយើងមិនអាចមិននិយាយបានទេថា សេដ្ឋកិច្ចទន់ខ្សោយរបស់ខ្លួនបានជំរុញឲ្យអ្នកកាសែតធ្វើការប្រុងប្រយ័ត្ននិងកាត់បន្ថយការរិះគន់នៅក្នុងអត្ថបទដ៏រសើបរបស់ខ្លួន។ ការបាត់បង់ការងារ ឬក៏ពាក្យបណ្ដឹងប្ដឹងស្ដីពីបទបរិហារកេរ្តិ៍បានធ្វើឲ្យសេដ្ឋកិច្ចរបស់គ្រួសារទាំងមូលរលំរលាយ។

គ្មានលុយ គ្មានរូបភាព នេះជាពាក្យដែលអ្នកថតរូប និងអ្នកថតទូរទស្សន៍មួយចំនួនឧស្សាហ៍និយាយឡើង។ ដោយសារហេតុផលប្រាក់ខែទាបដែលធ្វើឲ្យគេលំបាកក្នុងការទប់ទល់ចំណាយរហូតដាច់ខែ ពួកគេមួយចំនួននោះបានចរចាលុយកាក់ជាមួយអ្នកធំដែលចង់ចេញរូបរបស់ខ្លួននៅតាមបណ្ដាញផ្សព្វផ្សាយ។

ការអនុវត្តអំពើពុករលួយបានផ្ដល់នូវរូបភាពអាក្រក់ដល់វិជ្ជាជីវៈអ្នកកាសែត។ អង្គការអ្នកកាសែតព្យាយាមដោះស្រាយបញ្ហានេះ ជាពិសេសដោយមានការជួយគាំទ្ររបស់មូលនិធិរបស់Konrad Adenaueur។

បណ្ដាញផ្សព្វផ្សាយមានមធ្យោបាយតិចតួចដើម្បីអាចស៊ើបអង្កេតឲ្យបានស៊ីជម្រៅ ទៅលើរឿងដ៏រសើប។ អ្នកកាសែតក្នុងស្រុកម្នាក់បានពន្យល់ថា៖ ដោយខ្វះមធ្យោបាយ កាសែតរបស់ពួកយើងមានការលំបាកក្នុងការផលិតបទយកការណ៍ស៊ីជម្រៅ។ ក្នុងប្រធានបទទាក់ទងនឹងអំពើពុករលួយ និងការកាប់ព្រៃឈើ យើងមានលទ្ធភាពត្រឹមសុំការធ្វើអត្ថាធិប្បាយពីបក្សប្រឆាំងដើម្បីអាចបំពេញអត្ថបទរបស់យើង។ ម្យ៉ាងទៀត បើតាមចាងហ្វាងកាសែតម្នាក់ អ្នកកាសែតមិនហ៊ាន

សរសេររឿងដែលទាក់ទងនឹងធានាគារ ឬក៏ក្រុមហ៊ុនទូរស័ព្ទទេ ពីព្រោះក្រុមហ៊ុនទាំងនេះជាអ្នកធ្វើផ្សាយពាណិជ្ជកម្មក្នុងកាសែតរបស់ពួកគេ។

នៅមានបញ្ហាមួយទៀត។ អ្នកកាសែតភាគច្រើនមិនបានទទួលការបណ្តុះបណ្តាល។ បើតាមប្រធានក្លឹបអ្នកកាសែត អ្នកកាសែត ៨០ភាគរយដែលកំពុងធ្វើវិជ្ជាជីវៈ មិនយល់ដឹងពី ក្រមសីលធម៌ នៃវិជ្ជាជីវៈទេ។ បើតាមអ្នកកាសែតម្នាក់ដែលធ្លាប់បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាននៅសកលវិទ្យាល័យភ្នំពេញ មានអ្នកកាសែតតិចតួចណាស់ដែលបានទទួលការបណ្តុះបណ្តាល និងបំរើការនៅក្នុងបណ្តាញផ្សព្វផ្សាយ។

នៅក្នុងប្រទេសកម្ពុជា មិនមានសហជីពអ្នកកាសែតទេ។ ហេតុនេះហើយបានជាអ្នកកាសែតមានការលំបាកក្នុងការប្រមូលផ្តុំគ្នាតវ៉ាពីរឿងដ៏សំខាន់មួយនេះ។

## ករណីរបស់អ្នកកាសែត រស់ សូឃិត

អង្គការអ្នកយកពត៌មានគ្មានព្រំដែនបានធ្វើការស៊ើបអង្កេតទៅលើការចាប់ឃុំខ្លួនអ្នកកាសែតឯករាជ្យម្នាក់ឈ្មោះ រស់ សូឃិត។ ដោយយោលទៅតាមពាក្យបណ្តឹងរបស់សយ សុភាព ប្រធានកាសែត តុលាការបានផ្តន្ទាទោស រស់ សូឃិតឲ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំពីបទផ្តល់ព័ត៌មានមិនពិត។ សយ សុភាព បានបញ្ជាក់ប្រាប់ អង្គការអ្នកកាសែតគ្មានព្រំដែនថា ខ្លួនបានប្តឹងប៉ូលីសបន្ទាប់ពីបានទទួលសារ ទូរស័ព្ទ និងសារអ៊ីមែលគំរាមកំហែងមកលើលោក។ សយ សុភាព បាននិយាយថា ៖ ៝បើខ្ញុំបានដឹងថា គឺអ្នកកាសែតជាអ្នកផ្ញើរសារនោះ ខ្ញុំមិនធ្វើពាក្យបណ្តឹងទេ។

រស់ សូឃិត បាននិយាយផ្ទុយនឹងសំដីរបស់សយ សុភាព ដោយអះអាងថា សយ សុភាពស្គាល់លេខទូរស័ព្ទរបស់ខ្លួន ព្រោះពួកគេទាំងពីរធ្លាប់និយាយគ្នាទាក់ទងនឹងអត្ថបទដែលចុះផ្សាយនៅក្នុងទស្សនាវដ្ដីភាសាអង់គ្លេស Globeដែលមានមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។

រស់ សុឃិត ដែលកំពុងជាប់ឃុំក្នុងលក្ខ័ណ្ឌមួយដ៏លំបាក បានបញ្ជាក់ពីភាពមិនមានកំហុសរបស់ខ្លួន។ រស់ សូឃិតបាននិយាយថា ៖ ខ្ញុំបានទាក់ទងសយ សុភាព ដើម្បីសាកសួរព័ត៌មានបន្ថែមស្ដីពីបញ្ហាពុករលួយនៅក្នុងបណ្ដាញផ្សព្វផ្សាយ។ ខ្ញុំមិនដែលគំរាមសម្លាប់គាត់ទេ។

តាមពិតទៅ តុលាការមិនបានយកអ៊ីម៉ែលគម្រាមសម្លាប់ដែល គេបញ្ជូនមកពីបរទេស មកប្រើ ប្រាស់នៅក្នុងការជំនុំជម្រះក្ដីទេ។ រស់ សូឃិតដែលធ្លាប់បំរើការនៅក្នុងកាសែតក្នុងស្រុកជាច្រើនតាំងពីឆ្នាំ ១៩៩៣មកបាននិយាយថា ៖ ខ្ញុំមិនបានសម្លាប់អ្នកណាម្នាក់ទេ។ ខ្ញុំគ្រាន់តែព្យាយាមធ្វើការស៊ើបអង្កេតទៅលើការស៊ីសំណូកនៅក្នុងពិភពបណ្ដាញផ្សព្វផ្សាយប៉ុណ្ណោះ។ ប្រសិនបើគេកាត់ក្ដីខ្ញុំដោយមិនលំអៀង និងទៅតាមច្បាប់សារព័ត៌មាន នៅពេលនេះ ខ្ញុំប្រហែលជាស្ថិតនៅក្នុងគុកបែបនេះទេ។

អ្នកកាសែតនៅកាសែតឌឹ ខេមបូឌៀ ដេលីម្នាក់ដែលធ្លាប់ធ្វើការជាមួយរស់ សូឃិតបានបញ្ជាក់ថា ចៅក្រមបានប្រើប្រាស់បទចោទប្រកាន់ផ្សព្វផ្សាយមិនពិតដែលនេះមិនស៊ីគ្នាទៅនឹងរឿងដែលកំពុងកើតឡើងទាល់តែសោះ។ សម្រាប់លោក Tassilo Brinzer និពន្ធនាយករបស់ទស្សនាវដ្ដី Globeបញ្ជាក់ថា រស់ សូឃិត បានសរសេរព័ត៌មានយ៉ាងលំអិតស្ដីពីអំពើពុករលួយក្នុងចំណោមអ្នកកាសែត។ ក្នុងអត្ថបទនោះ រស់ សូឃិត ក៏បានស្រង់យកសំដីរបស់សយ សុភាពផងដែរ។ ប៉ុន្តែនាយករបស់ទស្សនាវដ្ដី Globeសោកស្ដាយថា រស់ សូឃិតបានផលិតកាតក្លែងក្លាយដោយដាក់ឈ្មោះរបស់ខ្លួនថា ជាអ្នកកាសែតរបស់ Globe។

អង្គការអ្នកយកពត៌មានគ្មានព្រំដែនប្រាថ្នាចង់ឲ្យសាលាឧទ្ធរណ៍ផ្តល់តម្លៃខ្លាំង និងស្តាប់អំណះអំណាងរបស់ភាគីដែលត្រូវគេចោទ។ ក្នុងករណីដែលអ្នកកាសែត សយ សុភាពបានបញ្ជាក់ប្រាប់អង្គការយកពត៌មានគ្មានព្រំដែនថា ខ្លួនមិនធ្វើពាក្យបណ្តឹង ប្រសិនបើខ្លួនដឹងថា ជាករណីនេះ ពាក់ព័ន្ធនឹងអ្នកកាសែតនោះ អង្គការអ្នកយកពត៌មានគ្មានព្រំដែនគិតថា គេគួរបោះបង់ចោលបទចោទប្រកាន់ដាក់បន្ទុក និងកំណត់មកត្រឹមធ្វើការស្តីបន្ទោសទៅលើរស់ សូខេតបានហើយ។

## មេឃាតករដែលបានប្រព្រឹត្តបទឧក្រិដ្ឋ កាលពីអតីតកាល ដែលគេមិននៅទាន់ចាប់បាន

រហូតមកដល់ថ្ងៃនេះ គេនៅមិនដែលចាប់បានឃាតករដែលបានសម្លាប់អ្នកកាសែតម្នាក់ណាទេ។ លោកឃឹម សម្បូរណ៍អ្នកកាសែតរបស់មនសិការខ្មែរ និងកូនប្រុសរបស់លោក អាយុ ២១ឆ្នាំ ត្រូវបានគេបាញ់សម្លាប់ នៅទីក្រុងភ្នំពេញ កាលពីថ្ងៃ ទី ១១ ខែ កក្កដា ឆ្នា ២០០៨។ ការបាញ់សម្លាប់នោះធ្វើឡើងនៅមួយថ្ងៃមុននៃការបោះឆ្នោតថ្នាក់ជាតិ។ អ្នកស៊ើបអង្កេតរបស់អង្គការលីកាដូម្នាក់បាននិយាយថា ៖ ភស្តុតាងដែលប្រមូលបាន បានបង្ហាញថា ឃាតកម្មដែលមានរៀបចំទុកមុន និងបញ្ជាពីអ្នកណាម្នាក់ មានពាក់ព័ន្ធនឹងអត្ថបទដែលចុះផ្សាយស្តីពីលោកហុក ឡង់ឌីអតីតមេប៉ូលីសជាន់ខ្ពស់កម្ពុជា។

នៅពីសប្តាហ៍មុននៃឃាតកម្មទៅលើអ្នកកាសែត និងកូនរបស់គាត់ កាសែតមនសិការខ្មែរបានចុះផ្សាយអត្ថបទមួយ (ដោយដូរឈ្មោះអ្នកកាសែត) ទាក់ទងនឹងប្រធាន ប៉ូលីសជាន់ខ្ពស់ម្នាក់។ គេមិនបានថា ប្រធានប៉ូលីសនោះឈ្មោះអ្វីទេ ប៉ុន្តែ

គេអាចដឹងយ៉ាងស្រួលពីអត្តសញ្ញាណរបស់ប៉ូលីសម្នាក់នោះនៅពេលកាសែតសរសេរថា មេប៉ូលីសជាតិគឺជា បុរសដែលគ្រោះថ្នាក់បំផុតសម្រាប់ប្រទេស។

មេប៉ូលីសម្នាក់នោះគឺប្រាកដជាហុក ឡង់ឌីដែលបានទៅចូលលេងល្បែងនៅកាស៊ីណូនៅបាវិតក្បែរព្រំដែនវៀតណាម កាលពីថ្ងៃ ទី២៥ ខែ មិថុនា ឆ្នាំ ២០០៨។ កាសែតបានសរសេរថា បន្ទាប់ពីចាញ់អស់លុយរបស់ខ្លួន មន្ត្រីម្នាក់នេះបានប្រើប្រាស់ការគំរាមកំហែងដើម្បីទទួលបានលុយខ្ចីពីកាស៊ីណូ។ ជាមួយគ្នានោះ មន្ត្រីមេប៉ូលីសម្នាក់នោះបានបញ្ជាឲ្យគេចាប់អ្នកទទួលខុសត្រូវម្នាក់របស់កាស៊ីណូដែលបដិសេធមិនផ្តល់ប្រាក់ខ្ចីបន្ថែម។

ហុក ឡង់ឌីបានស្លាប់នៅក្នុងគ្រោះថ្នាក់ធ្លាក់ឧទ្ធម្ភាគចក្រមួយ ហើយការស៊ើបអង្កេតទៅលើគ្រោះថ្នាក់នេះមិនបានបន្តទៅមុខទេ។ ការិយាល័យ ប៉ូលីសសហព័ន្ធ FBIរបស់អាមេរិកដែលធ្លាប់បានចូលខ្លួនស៊ើបអង្កេតមួយរយៈ បានដកខ្លួនចេញភ្លាមៗ បន្ទាប់ពីមានការបង្ហើបក្នុងកាសែតថា ករណីស្លាប់នេះពាក់ព័ន្ធនឹងរឿងលាក់កំបាំងដែលគេមិនចង់បង្ហាញ។ ចំណែកលោក ដាំ សិទ្ធចាងហ្វាងកាសែតនិយាយថា ករណីឃាតកម្មនេះ គឺជាការវាយប្រហារមកលើកាសែតរបស់លោក។ កាសែតដែលកំពុងស្ថិតក្នុងការព្យួរមិនចេញផ្សាយនៅឡើយ។

មុនករណីឃាតកម្មមកលើលោកឃឹម សម្បូរណ៍ អ្នកកាសែតផ្សេងទៀតដែលមានស្និទនឹងកាសែតប្រឆាំងត្រូវបានគេសម្លាប់ ហើយរហូតមកដល់ពេលនេះ គេមិនទាន់ចាប់បានមេឃាតករណាម្នាក់ទេ។ យើងអាចលើកយកករណីសម្លាប់នៅឆ្នាំ ២០០៣ ទៅលើលោកជួរ ជេដ្ឋារិទ្ធ អ្នកនិយាយព័ត៌មានរបស់វិទ្យុតាព្រហ្ម និងករណីរបស់អ្នកកាសែត ៤នាក់ផ្សេងទៀតដែលត្រូវគេសម្លាប់នៅក្នុងកំឡុងពេលបោះឆ្នោតឆ្នាំ ១៩៩៧។

ជាមួយគ្នានេះផងដែរ ប៉ូលីសមិនបានកំណត់អត្តសញ្ញាណរបស់អ្នកដែលបានគំរាមសម្លាប់ទៅលើអ្នកកាសែតដែលបានធ្វើការស៊ើបអង្កេតទៅលើរឿងកាប់ព្រៃឈើខុសច្បាប់ និងការចូលរួមពាក់ព័ន្ធរបស់មន្ត្រីអាជ្ញាធរក្នុងការដួញដូរទាំងនោះទេ។ ឧទាហរណ៍ លឹម ពិសិដ្ឋ កំពុងគេចខ្លួននៅបរទេសនៅឡើយ បន្ទាប់ពីបានទទួលការគំរាមសម្លាប់កាលពីឆ្នាំ ២០០៧។ លឹមពិសិដ្ឋបានសរសេររឿងស៊ើបអង្កេតទាក់ទងនឹងការកាប់ព្រៃឈើក្នុងខេត្តកំពង់ធំ។ នៅសម័យនោះ លឹម ពិសិដ្ឋ គឺជាអ្នកឆ្លើយឆ្លងព័ត៌មានរបស់វិទ្យុអាស៊ី សេរីប្រចាំប្រទេសកម្ពុជា។

បើទោះបីជាសារព័ត៌មានមិនត្រូវបានទទួលការត្រួតពិនិត្យ និងមានសេរភាពក្នុងការសរសេររឿងទាក់ទងនឹងការកាប់ព្រៃឈើ ប៉ុន្តែ គេមានការលំបាកក្នុងការស្វែងរកព័ត៌មានស្តីពីឈ្មោះរបស់អ្នកទទួលខុសត្រូវ និងបណ្តាញដែលពាក់ព័ន្ធនឹងការកាប់ព្រៃឈើ។ លោកប៉ែន សមិទ្ធី បានបញ្ជាក់ថា ៖ «សឹងជារឿងរាល់ថ្ងៃកាសែតយើងសរសេររឿងកាប់ព្រៃឈើ ប៉ុន្តែ យើងត្រូវការជំនួយគាំទ្រពីបរទេសដើម្បីអាចការពារអ្នកកាសែតដែលធ្វើរឿងស៊ើបអង្កេតទៅលើរឿងដ៏រសើបទាំងនោះ។ ការផ្តល់ការការពារអ្នកកាសែត គឺជាទំងន់ហិរញ្ញវត្ថុមួយដ៏ធំសម្រាប់កាសែត»។

រឿងនេះបានក្លាយជាករណីផ្ទាល់របស់និពន្ធនាយករបស់កាសែតមាតុភូមិ។ និពន្ធនាយករបស់កាសែតមួយនេះកំពុងមន្ត្រីទាហានខេត្តក្រចេះម្នាក់ដាក់ពាក្យបណ្តឹងពីបទបរិហារកេរ្តិ៍ នៅពេលដែលកាសែតបានសរសេរថា មន្ត្រីរូបនេះជាប់ពាក់ព័ន្ធនឹងការកាប់ព្រៃឈើ។

## ការសន្និដ្ឋាន និងអនុសាសន៍

អង្គការអ្នកយកពត៌មានគ្មានព្រំដែនស្វាគមន៍ជំហររបស់រដ្ឋាភិបាលដែលបានសម្រេចចិត្តលុបចោលទោសជាប់ពន្ធនាគារទៅដល់បទល្មើសដែលពាក់ព័ន្ធនឹងសារព័ត៌មាន។ អង្គការអ្នក យក ពត៌មានគ្មានព្រំដែនចាត់ទុកថា ការសម្រេចចិត្តនេះថា ជាការបោះជំហានទៅមុខនៃការលើកទឹកចិត្ត នៅក្នុងបរិបទដែលស្ថានភាពសារព័ត៌មានក្នុងតំបន់កំពុងជួបការលំបាក។ ប៉ុន្តែ ការចាប់ អ្នកកាសែតប្រឆាំង ដាក់គុក បានបង្ហាញយ៉ាងឃោឃៅថា ការសន្យាមិនត្រូវបានគោរពនោះទេ។ ការបោះបង់ចោលការសន្យានេះអមទៅជាមួយនឹងការបៀតបៀនតាមរយៈតុលាការទៅលើអ្នកប្រឆាំង និងអ្នកកាសែត។ សហគមន៍អន្តរជាតិបានរិះគន់ការដើរថយក្រោយនេះ។ រដ្ឋាភិបាលកម្ពុជារបស់លោក ហ៊ុន សែន នៅមានពេលនៅឡើយដើម្បីធ្វើឲ្យប្រសើរឡើងវិញ នូវស្ថានភាពសេរីភាពសារព័ត៌មាន។

មានសញ្ញាគួរឲ្យលើកទឹកចិត្តមួយ នោះគឺ បណ្ដាញផ្សព្វផ្សាយព័ត៌មានកម្ពុជាអាចតាមដានសរសេរអត្ថបទស្ដីពីកាត់ទោសអតីតមេដឹកនាំរបបប៉ុលពត។ Thierry Cruvellier បានចូលរួមបណ្ដុះបណ្ដាលអ្នកកាសែតខ្មែរ ដើម្បីធ្វើយ៉ាងណាឲ្យពួកគេបានយល់ដឹងពីបញ្ហាដែលអាចកើតឡើងក្នុងតុលាការអន្តរជាតិ។ លោកបានពន្យល់ថា ៖ “ក្រៅតែពីមានបញ្ហាទីតាំង និងចំងាយឆ្ងាយរបស់សាលាក្ដី ពីទីក្រុងភ្នំពេញ អ្នកកាសែតកម្ពុជាអាចតាមដានយកព័ត៌មានពីសាលាក្ដី ដោយមិនមានការលំបាក។ ប៉ុន្តែ ទោះជាយ៉ាងណា ការពាក់ព័ន្ធរបស់មន្ត្រីជាន់ខ្ពស់មួយចំនួននឹងរបបខ្មែរក្រហម នៅតែជារឿងមួយដ៏រសើប។

លោក Thierry Cruvellierបាននិយាយបញ្ជាក់បន្ថែមថា ៖ “សារព័ត៌មានត្រូវបានព្រមានតាំងពីដើមទី មិនឲ្យចេញផ្សាយឯកសារសំងាត់របស់សាលាក្ដីអន្តរជាតិ បើមិនដូច្នោះទេ ពួកគេនឹងត្រូវទទួលការពិន័យដ៏ធ្ងន់។ ឧបទ្ទហេតុបែបនេះបាន

កើតឡើងនៅ ឆ្នាំ ២០០៧ និងឆ្នាំ ២០០៨ ជាពិសេសវាបានកើតឡើងទៅលើទីភ្នាក់ងារព័ត៌មានបរទេស។ គេបានគំរាមប្ដឹងទីភ្នាក់ងារព័ត៌មាន ឬគំរាមមិនឲ្យចូលក្នុងសាលាក្ដី ប្រសិនបើទីភ្នាក់ងារចេញផ្សាយឯកសារសំងាត់នោះ។ គួរឲ្យសោកស្ដាយ ដែលនិន្នាការបែបនេះកើតមាននៅក្នុងសាលាក្ដី អន្តរជាតិ។

យើងអាចស្វាគមន៍ការវិវត្តន៍ជាវិជ្ជមានដទៃទៀត ជាពិសេសគឺការបណ្ដុះបណ្ដាលអ្នកនាំពាក្យប្រចាំក្រសួងនីមួយៗ។ ជាមួយគ្នានោះ គេក៏បានកត់សំគាល់ឃើញថា មិនទាន់មានការតាមដានត្រួតពិនិត្យអាំងទែណេត។ ប៉ុន្តែ បើតាមប្រភពជាច្រើន រដ្ឋាភិបាលកំពុងគ្រោងធ្វើសេចក្ដីព្រាងច្បាប់ដើម្បីរៀបចំត្រួតពិនិត្យលើខ្លឹមសារក្នុងអាំងទែណេត។ សេចក្ដីព្រាងច្បាប់នោះបានបញ្ចូលផងដែរនូវវិធានការដាក់ពិន័យ ចំពោះខ្លឹមសារណាដែលប្រមាថដល់ព្រះមហាក្សត្រ និងប៉ះពាល់ដល់ប្រពៃណី។

ប៉ុន្តែ លោកហ៊ុន សែន និងសម្ព័ន្ធមិត្តរបស់ខ្លួនដែលត្រូវបានពង្រឹងតាមរយៈការបោះឆ្នោត ឆ្នាំ ២០០៨ និងតាមរយៈការជួយគាំទ្រពីប្រទេសចិន ព្យាយាមបំបាក់ស្មារតីរបស់អ្នកកាសែត គណបក្សប្រឆាំង និងសកម្មជនសិទ្ធិមនុស្ស ដែលនិយាយឬសរសេរប្រធានបទរសើបដែលទាក់ទងនឹងភាពតានតឹងនៅតាមព្រំដែន។ វិធានការនេះមានទិសដៅផ្ទុយនឹងអនុសាសន៍របស់អង្គការសហប្រជាជាតិ ជាពិសេសផ្ទុយនឹងអនុសាសន៍របស់អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិទទួលបន្ទុកសេរីភាពបញ្ចេញមតិ។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានអំពាវនាវកាលពីពេលថ្មីៗនេះដល់មន្ត្រីឲ្យបញ្ឈប់ធ្វើការប្ដឹងផ្ដល់អ្នកកាសែតនៅតុលាការទៀត។

## អនុសាសន៍ដល់រដ្ឋាភិបាលកម្ពុជា៖

១. ដោះលែងជាបន្ទាន់លោកហង្ស ចក្រា ចាងហ្វាងកាសែតខ្មែរម្ចាស់ស្រុក និង ត្រៀមរៀបចំរយៈពេលសមរម្យណាមួយដើម្បីបើកសវនាការទៅតាមការប្ដឹងឧទ្ធរណ៍របស់អ្នកកាសែត រស់ សូឃិត។
២.ពង្រឹងវិចារណកថារបស់បណ្ដាញព័ត៌មានរដ្ឋឲ្យមានភាពឯករាជ្យ ទូរទស្សន៍ TVK វិទ្យុ ៩១៨AM ៩៦FM ដោយផ្ដល់លក្ខន្តិកៈឯករាជ្យ ផ្ដាច់ចេញពីការគ្រប់គ្រងរបស់ក្រសួងព័ត៌មាន។
៣. បញ្ឈប់ដាក់គំនាបទៅលើអ្នកធ្វើអាជីវកម្មដែលចង់ធ្វើការផ្សាយពាណិជ្ជកម្មនៅក្នុងកាសែតប្រឆាំង។
៤. ធ្វើការស៊ើបអង្កេតជាថ្មីទៅលើការបាញ់សម្លាប់អ្នកកាសែត ឃឹម សម្បូរណ៍ និងស្វែងរកអ្នកដែលបានគំរាមសម្លាប់លោកលឹម ពិសិដ្ឋ អ្នករាយការណ៍របស់វិទ្យុអាស៊ី សេរី។
៥. បញ្ឈប់ការលួចស្ដាប់ការសន្ទនាតាមទូរសព្ទ័របស់អ្នកកាសែត។

## អនុសាសន៍សម្រាប់ក្រសួងយុត្តិធម៌៖

៦. ត្រូវធានាថា ក្រមព្រហ្មទណ្ឌថ្មីនឹងមិនមានចរិតដាក់ពិន័យ (ដូចជាទោសដាក់គុក និងពិន័យជាប្រាក់ដ៏ច្រើនក្រាស់ក្រែល) ក្នុងករណីបទល្មើសទាក់ទឹងនឹងសារព័ត៌មាន
៧.ពិនិត្យឡើងវិញរាល់ពាក្យបណ្ដឹងស្ដីពី ៉ការផ្សាយព័ត៌មានមិនពិត៉ និង ៉ការញុះញង់៉ ដែលធ្វើឡើងដោយមេធាវីរបស់រដ្ឋាភិបាល។ ក្រសួងត្រូវធ្វើយ៉ាងណាឲ្យពាក្យបណ្ដឹងនោះត្រូវចាត់ការដោយប្រើច្បាប់សារព័ត៌មាន។
៨. ចាប់ផ្ដើមការងារផ្នែកច្បាប់ដើម្បីពង្រឹងមាត្រា ទី ១២ នៃច្បាប់សារព័ត៌មាន។ មាត្រានេះបានកំណត់សេរីភាពជាមូលដ្ឋានរបស់អ្នកកាសែត ដោយប្រើហេតុផលការការពារសន្តិសុខជាតិ និងស្ថិរភាពនយោបាយ។

## អនុសាសន៍ដល់រដ្ឋមន្ត្រីក្រសួងព័ត៌មាន៖

៩.បង្កើតស្ថាប័នឯករាជ្យមួយដើម្បីរៀបចំគ្រប់គ្រងបណ្តាញផ្សព្វផ្សាយ សោតទស្សន៍ ជាពិសេសដើម្បីផ្តល់អាជ្ញាប័ត្របង្កើតវិទ្យុ និងទូរទស្សន៍។

១០.យកទៅពិចារណានូវអនុសាសន៍របស់ក្លឹបអ្នកកាសែតកម្ពុជា ស្តីពីការចែកចាយអត្តសញ្ញាណប័ណ្ណអ្នកកាសែត។

១១.បង្ហាញជាសាធារណៈនូវគំរោងព្រាងច្បាប់ស្តីពីការគ្រប់គ្រងខ្លឹមសារអាំងទែណែត។

## អនុសាសន៍សម្រាប់អង្គការអ្នកកាសែត៖

១២.ប្រមូលផ្តុំគ្នាជាសម្ពន្ធដើម្បីអាចមានសមត្ថភាពរៀបចំដោះស្រាយរវាងគ្នាក្នុងបណ្តាញផ្សព្វផ្សាយ

១៣.ចាប់ផ្តើមសកម្មភាពដើម្បីបញ្ចុះបញ្ចូលឲ្យគេឲ្យតម្លៃដល់លក្ខ័ណ្ឌការងាររបស់អ្នកកាសែត ជាពិសេស ធ្វើយ៉ាងណាដើម្បីឲ្យអ្នកកាសែតបានទទួលកិច្ចសន្យា និងប្រាក់កំរៃសមរម្យ។

## អនុសាសន៍សម្រាប់បណ្តាញផ្សព្វផ្សាយកម្ពុជា៖

១៤.គោរពក្រមសីលធម៌សារព័ត៌មាន ដោយសរសេរឲ្យមានតុល្យភាពនូវរឿងនយោបាយ ជៀសវាងពល់ការធ្វើវិនិច្ឆ័យទុកមុន និងប្រើសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួន។

## អនុសាសន៍ដល់សហគមន៍អន្តរជាតិ៖

១៥.ជួយការពារដើម្បីសេរីភាពជាបន្ទាន់របស់អ្នកកាសែត ហង្ស ចក្រា និងជួយការពារដើម្បីឲ្យគេបោះបង់ចោលនូវការធ្វើបណ្តឹងដែលរំលោភដល់អ្នកកាសែត។

១៦.ផ្តល់ជំនួយជាសំភារៈ និងហិរញ្ញវត្ថុដល់បណ្តាញផ្សព្វផ្សាយឯករាជ្យ និងដល់អង្គការអ្នកយកព័ត៌មាន៕